ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 06 / 2015
ម៉ោង (Time/Heure): 15:05
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

## កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

ថ្ងៃ ពុធ ទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥

## សវនាការលើភ័ស្តុតាង - ថ្ងៃ ២៨៧

រៀបចំដោយ៖ សែ កុលវុឌ្ឍី និង **Matthew J. McCARTHY**

| |
|---|
| **កំណត់ហេតុអ្នកចូលរួម** |
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក Matthew J. McCARTHY |
| ការិយាល័យសហព្រះរាជអាជ្ញា៖ កញ្ញា សុង ឆវ័ន្ត, លោក Dale LYSAK |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អារុណ, លោក លីវ សុវណ្ណ, លោក Victor KOPPE |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin Saunders |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក វេ៉ន ពៅ, លោកស្រី ម៉ុច សុវណ្ណារី |

| |
|---|
| សាក្សី/ដើមបណ្ដឹង៖ លោកស្រី ហ៊ុន សិត្ថានី (2-TCCP-255), លោកស្រី អ៊ុន វ៉ន (2-TCCP-230) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី ស្ងួ សុទ្ធាវី |
| ផ្សេងៗ៖ លោកស្រី សំ មករា, លោក នូ មនោរ័ត្ន, លោក Sheriffo JAMMEH, លោក Laurent SOULARD, លោក លី សុតុល្យ, កញ្ញា Joelle TRAMPERT |

**ពេលវេលាទូទៅរបស់តុលាការ៖**

| | | |
|---|---|---|
| ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ | ចាប់ផ្ដើមម៉ោង៖ ០៩.០១ | បញ្ចប់ម៉ោង៖ ១៦.០២ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.១០ | បញ្ចប់ម៉ោង៖ ១០.៣៣ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣៤ | បញ្ចប់ម៉ោង៖ ១៣.៣២ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤៦ | បញ្ចប់ម៉ោង៖ ១៥.០២ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ២៤ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០១ | ០៩.០៣ |
| សំណើរបស់ នួន ជា ស្នើសុំចូលរួមកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.០៣ | ០៩.០៥ |
| ការតាំងសំណួរបន្តទៅដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី (2-TCCP-255) | មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី<br>សហព្រះរាជអាជ្ញា<br>មេធាវីការពារក្ដី នួន ជា<br>មេធាវីការពារក្ដី ខៀវ សំផន | ០៩.០៥<br>១០.០២<br>១១.១៥<br>១៥.០៣ | ១០.០២<br>១១.១៤<br>១៤.៤៦<br>១៥.២៣ |
| ការតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន វ៉ន (2-TCCP-230) | អង្គជំនុំជម្រះ<br>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ១៥.៣៨<br>១៥.៤១ | ១៥.៤០<br>១៦.០១ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ដោយឡែកជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំចូលរួមកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**ការតាំងសំណួរបន្តទៅដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី (2-TCCP-255)**

សហមេធាវីនាំមុខ សហព្រះរាជអាជ្ញា មេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី ខៀវ សំផន បានធ្វើការតាំងសំនួរទៅដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី (2-TCCP-255)។ បន្ទាប់មកដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនាដែលគាត់ទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងបានតាំងសំណួរទៅកាន់ជនជាប់ចោទ។ អង្គជំនុំជម្រះបានជូនដំណឹងទៅដើមបណ្តឹងរដ្ឋប្បវេណីថា ជនជាប់ចោទទាំងពីររូបបានប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប។

**ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ វ៉ន (2-TCCP-230)**

អង្គជំនុំជម្រះបានធ្វើការតាំងសំណួរបឋមមួយចំនួនទៅដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ វ៉ន (2-TCCP-230)។ បន្ទាប់មក សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការតាំងសំណួរបន្តទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/4790 | | 00582090-00582100; 00940138-00940145; 00967204-00967212 | Supplementary information of civil party applicant | P | 00582091<br>00582092<br>00582093<br>00582095<br>00582096<br>00582097 | 00940139<br>00940140<br>00940141<br>00940142<br>00940143<br>00940144 | 00967205<br>00960206<br>00960207<br>00960208<br>00960209 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/403 | | 00389519-00389530; 00403001-00403011; 00422235-00422246 | Written Record of Interview of PECH Sokha | P | 00389524 | 00403006 | 00422240 |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៥)
- បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់អោយនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញអោយបានមុនម៉ោង ៩.00 ព្រឹក នៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥។ (១៦.០២)

**កាលវេលាសវនាការបន្ត**

សវនាការនឹងបន្តទៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ០៩.00 ព្រឹក។

ភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ កុលទុន្ទ... Matthew J. McCARTHY